# អនុក្រឹត្យ

# ស្តីពី

# តួនាទី ភារកិច្ច និង

# រចនាសម្ព័ន្ធ របស់មជ្ឈមណ្ឌល

# គ្រប់គ្រងយុវទោសករ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# I- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទិ ១៩ ខែមេសា ឆ្នាំ១៩៩៤

# អនុក្រឹត្យលេខ ១៧ អនក្រ

**ស្តីពី**

**តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ**

**របស់ មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមនសីហនុវរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាជាម្ចាស់ជីវិតលើត្បូង ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ត្រាស់បង្គាប់តែងតាំងប្រតិភូ នៃរាជរដ្ឋាភិបាល ទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ

**សំរេច**

**មាត្រា ១.-**

មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ "យុវនីតិសម្បទា" ជាស្ថាប័នចំណុះរាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចគ្រប់គ្រងក្មេងពីអាយុ ៧ឆ្នាំ ដល់ ១៧ឆ្នាំ ប្រព្រឹត្តអំពើអបាយមុខ -ចោរកម្ម ក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែ អភិវឌ្ឍន៍ធន

ធានមនុស្ស អោយមានការរីកចំរើនទាំងជីវភាព ខាងស្មារតី និងសំភារៈ ដោយប្រែក្លាយពីជនគ្មានវិន័យ គ្មានសីលធម៌ ...... ទៅជាពលរដ្ឋស្អាតស្អំប្រកបដោយវិន័យថ្លៃថ្នូរ ។

**មាត្រា ២.-**

មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ មានភារកិច្ចសំខាន់ៗ ដូចតទៅ :

- ចូលរួមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលយកក្មេងដែលប្រព្រឹត្តិអំពើអបាយមុខ ចោរកម្មមកគ្រប់គ្រង និងស្រាវជ្រាវរកក្រុមគ្រួសារ អាណាព្យាបាលរបស់គេ ដោយធ្វើកោសល្យវិច័យ ។
- បែងចែកការគ្រប់គ្រងតាមកំរិត កំហុសដែលប្រព្រឹត្ត ,វ័យ ,ភេទ ។
- អប់រំសីលធម៌រស់នៅ ដើម្បីប្រែក្លាយគេអោយទៅជាពលរដ្ឋល្អថ្លៃថ្នូរ សំរាប់សង្គមជាតិ ។
- អប់រំបំពេញវិជ្ជា និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរូបភាព អញ្ជើញគ្រូរបស់ក្រសួងអប់រំ យុវជន និងកីឡា មកជួយ ឬជួលគ្រូបង្ហាត់ជំនាញដូចជា កាត់ដេរ ជួសជុលគ្រឿងយន្ត ជាងឈើ ជាងកំបោរ កែច្នៃ

គ្រឿងសង្ហារឹម ដាំដុះ ចិញ្ចឹមសត្វ ។ល ។និងមានផ្តល់ជាលិខិតទទួលស្គាល់មុខវិជ្ជាជីវៈ សំរាប់សំរួលដល់ការទៅរកប្រកបរបរចិញ្ចឹមជីវិតរបស់គេ នៅពេលវិលទៅរួមរស់ជាមួយគ្រួសារ និងអាណាព្យាបាល ។

- សហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមនានា ដើម្បីអភិវឌ្ឍន៍មជ្ឈមណ្ឌល ។

**មាត្រា ៣.-**

រចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលរួមមាន :

១-ខុទ្ទកាល័យ

២-នាយកដ្ឋានបណ្តុះបណ្តាល

៣-នាយកដ្ឋានគ្រប់គ្រង

៤-នាយកដ្ឋានទំនាក់ទំនងជំនួយ

រចនាសម្ព័ន្ធនេះមានការកែប្រែទៅតាមករណីជាក់ស្តែង ។

ខុទ្ទកាល័យ នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៤.-**

ការរៀបចំតួនាទី ភារកិច្ច និងសិទ្ធិរបស់ខុទ្ទកាល័យ នាយកដ្ឋាន និងការិយាល័យនិមួយៗ ត្រូវកំណត់ដោយប្រកាសរបស់មជ្ឈមណ្ឌល ។

**មាត្រា ៥.-**

មជ្ឈមណ្ឌល អាចចេញប្រកាសរួម ក្នុងនាមអន្តរក្រសួងលើករណី មានការចាត់តាំងដល់តួនាទីភារកិច្ច សិទ្ធិអំណាចរបស់ខ្លួនជាមួយក្រសួង ស្ថាប័នផ្សេងៗទៀត ។

**មាត្រា ៦.-**

ក្របខ័ណ្ឌ មន្ត្រី បុគ្គលិករាជការ និងទីប្រឹក្សា ឧបការី របស់មជ្ឈមណ្ឌល ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៧.-**

ការចំណាយទាំងអស់សំរាប់សកម្មភាពរបស់មជ្ឈមណ្ឌលជាបន្ទុករបស់ថវិកាជាតិ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូនៃរាជរដ្ឋាភិបាលទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវ ទោសករ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងគ្រប់រដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៩.-**

អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហត្ថលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះសហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

# រចនាសម្ព័ន្ធមជ្ឈមណ្ឌលគ្រប់គ្រងយុវជនទោសករ

## “យុវនីតិសម្បទា”

